វិទ្យាស្ថានជាតិអប់រំ

Moral Civic Education -NIE

# វិធីឧទ្ទេស

## LECTURE METHOD



# វិធីសាស្ត្របង្រៀនបែបឧទ្ទេស

# Lecture Method

## I. វិធីសាស្ត្របែបឧទ្ទេស

*វិធីឧទ្ទេស ជាវិធីមួយដែលគ្រូប្រើសម្ដីមេរៀនថ្មី។ វិធីឧទ្ទេសជាវិធីដែលគ្រូយកមកប្រើប្រាស់ជាមធ្យោបាយ និងជាមូលដ្ឋាននៅក្នុងការអនុវត្តន៍តាមលំនាំនៃការបង្រៀនពេលវិធីនេះទាម ទារឲ្យគ្រូបង្រៀនចេះប្រើប្រាស់វាថាយ៉ាងរស់រវើក និងសម្បូរទៅដោយរូបារម្មណ៍ ដើម្បីទាក់ទាញទឹកចិត្ត និងចំណាប់ចំណូលចិត្តរបស់សិស្ស ។ វិធីឧទ្ទេស គឺជាវិធីមួយដែលតម្រូវឲ្យគ្រូបង្រៀនធ្វើសកម្មភាពច្រើនជាងសកម្មភាពសិស្ស ហើយសិស្សអង្គុយចាំស្ដាប់គ្រូពន្យល់ និងកត់ត្រាសំណួរ ឬខ្លឹមសារមេរៀន ឬចំណុចសំខាន់នៃមេរៀនទុក ហើយគ្រូផ្ទាល់ត្រូវចេះបង្កើតសំណួរទៅកាន់សិស្ស ដើម្បីវាស់ស្ទង់សិស្សផង និងដើម្បីកុំឲ្យស្ងាត់ផង។ វិធីនេះត្រូវបានចែកជាវិធីជាក់ស្ដែងដូចតទៅ: ការធ្វើអត្ថាធិប្បាយ វិធីបំណកស្រាយពន្យល់ និងវិធីបែបពិពណ៌នា ។*

### ១. សញ្ញាណទូទៅ

### ក. វិធីអត្ថាធិប្បាយ

*ជាវិធីដែលគ្រូប្រើពាក្យសម្ដី ដើម្បីបកស្រាយបញ្ញត្តិ ភេទ ក្រិត្យក្រម និងរបៀបប្រើប្រាស់ក្រិត្យក្រមទាំងនេះ។ វិធីនេះ គឺជាការរៀបរាប់ពីបញ្ហាមួយដើម្បីបំពេញឬបង្គ្រប់ទៅលើចំណេះដឹង ដែលមានភាពស្មុគស្មាញ អរូបី ដែលត្រូវបានធ្វើទូទៅកម្មនៅ ក្នុងរយៈពេលមួយដ៏ខ្លី។*

### ខ. វិធីបំណកស្រាយពន្យល់

*ជាបំរើបំរាស់ទិន្នន័យ ដើម្បីស្រាយបំភ្លឺពីគោលការណ៍ វិធាន ទ្រឹស្ដីបទ ក្រឹត្យក្រមនិងរូបមន្តនៅក្នុងមុខវិជ្ជាសិក្សា គណិតវិទ្យា រូបវិទ្យា គីមីវិទ្យានិងវេយ្យាករណ៍ជាដើម។ នៅក្នុងវិធីនេះសាស្ត្រាចារ្យ គប្បីប្រើប្រាស់គ្រប់កត្តាទាំងអស់ ក្នុងវិចារណញ្ញាណនិងក្នុងការវិនិច្ឆ័យ ដើម្បីឲ្យមានសមត្ថភាពគ្រប់គ្រាន់ និងយ៉ាងប៉ិនប្រសប់ក្នុងការពង្រីកចំណេះដឹង ភាពឈ្លាសវៃនិងចរិតច្នៃប្រឌិតរបស់សិស្ស។*

**គ. វិធីសាស្ត្រពិពណ៌នា**

ជាវិធីមួយក្នុងចំណោមវិធីនទទ្ទេស ដែលមានកត្តាសំខាន់របស់វាគឺ ការនិទានរឿងនិងពណ៌នានេះឯង។ វិធីនេះគ្រូប្រើប្រាស់ពាក្យសម្តី ដើម្បីផ្ទេរចំណេះដឹងដល់សិស្សដែរ ។ ប៉ុន្តែបើប្រៀបធៀបទៅនិងវិធីខាងលើ វិធីពិពណ៌នាមានចរិតជាក់ស្តែងជាង មានប្រព័ន្ធជាងតែវាក៏ត្រូវចំណាយពេលវេលាច្រើនផងដែរ។ ប៉ុន្តែវាក៏មានគុណវិបត្តផងដែរ ដូចនេះគ្រូត្រូវយកចិត្តទុកដាក់ផងពេលប្រើវិធីនេះគឺ គប្បីផ្សំជាមួយវិធីផ្សេងៗទៀត ដូចជាវិធីសន្ទនាជាដើម។

**២. បញ្ហាមួយចំនួនដែលគ្រូត្រូវយកចិត្តដាក់ពេលប្រើវិធីនេះ**

**២.១ ពាក្យសម្តីរបស់គ្រូ :** យើងដឹងហើយថាមធ្យោបាយសំខាន់នៃ វិធីនេះគឺពាក្យសម្តីរបស់គ្រូ។ ការដែលគ្រូប្រើពាក្យសម្តីបកស្រាយគំនិត ដើម្បីផ្ទេរចំណេះដឹងទៅសិស្សគប្បីប្រុងប្រយ័ត្ននូវប្រការទាំងឡាយដូចខាងក្រោម:

**ក. ចរិតជាក់លាក់ក្នុងការបញ្ចេញសំឡេង**

ដើម្បីបន្ថយនូវគុណវិបត្តិ គ្រូត្រូវយកចិត្តទុកដាក់ដល់ការបញ្ចេញសំឡេង ពោលគឺនិយាយឲ្យច្បាស់ៗ ឃ្លាប្រយោគក៏ត្រូវគោរពវេយ្យាករណ៍។

**ខ. ការបង្កើតសញ្ចេតនាក្នុងការប្រើពាក្យសម្តី**

ពាក្យសម្តីដែលមានមនោសញ្ចេតនា អាចជះឥទ្ធិពលដល់សញ្ចេតនា និងឆន្ទៈរបស់សិស្ស។ មនោសញ្ចេតនាក្នុងពាក្យសម្តីបង្រៀន វាចំណុះឲ្យកត្តាជាច្រើនដូចជាការប្រើប្រាស់រូបារម្មណ៍ក្នុង ពាក្យពេចន៍ ឃ្លោងឃ្លា ដែលត្រូវបង្រៀន។

**គ. ល្បឿន និងកម្រិតរបស់ពាក្យសម្តី**

នេះជាសំណូមពរគរុកោសល្យមួយដែរ។ ការបង្រៀនទទួលផលល្អលុះត្រាតែសិស្សអាចស្តាប់បានច្បាស់ និងអាចកត់ត្រាបាននូវចំនុចណាដែលសិស្សត្រូវកត់ត្រា។

**២.២ ខ្លឹមសារមេរៀន**

គ្រូត្រូវជ្រើសរើសយកខ្លឹមសារសំខាន់មកបង្រៀន។ ការបង្រៀនគឺ ស្ថិតត្រង់សិស្សអាចក្តាប់យកខ្លឹមសារមេរៀន ហើយអាចយកចំណេះដឹងនោះទៅប្រើប្រាស់ និងយកមកធ្វើជាទស្សនៈរបស់ខ្លួន។

**២.៤ អាកប្បកិរិយា ឫតពាររបស់គ្រូ**

ក្នុងសាលារៀនប្រការដែលសំខាន់ គឺទិសដៅកម្មវិធីសិក្សា និងខ្លឹមសារមេរៀន។ តែអ្នកដែលធ្វើឲ្យបានសម្រេចបំណងនេះ គឺអ្នកបង្រៀន។ ក្នុងការបង្រៀនទស្សនវិជ្ជាទាមទារឲ្យអ្នកបង្រៀនមានអាកប្បកិរិយា ឬកពារសមរម្យជាអ្នកមានសីលធម៌។

**២.៣ ការប្រើប្រាស់វិធីពិចារណាសមហេតុផល**

ទ្រឹស្តីពុទ្ធិបានបង្ហាញថា ការពិចារណាសមហេតុសមផលជាប្រការដែលមានអត្ថន័យផ្ទាល់ពេលដែលគេប្រើវិធីឧទ្ទេស។ វិធីពិចារណាអរូបីយដែលសមស្របទៅនិងការបង្រៀនទស្សនវិជ្ជាជាមុខវិជ្ជា ដែលមានចរិកឧភាសកម្ម និងអរូបីយ។

**ក. វិភាគ-សំយោគ**

-វិភាគ: ជាវិធីមួយដែលគេកាត់បំបែកវត្ថុ ឬបាតុភូតទៅជាផ្នែកៗដើម្បីស្រាវជ្រាវ។

-សំយោគ: គឺជាការផ្អែកលើលទ្ធផលនៃការវិភាគដែលត្រូវបានធ្វើឧភាកម្ម ប្រមូលផ្តុំបញ្ចូលគ្នានូវការជះឥទ្ធិពលឲ្យគ្នាទៅវិញទៅមក ដើម្បីមើលឲ្យឃើញសារជាតិរបស់វត្ថុបាតុភូតនោះទាំងមូល។

**ខ. អនុមានរួម-អនុមានញែក**

-អនុមានរួម: ជាវិធីមួយដែលចេញដំណើរពីភាពដោយឡែកទៅរកភាពរួម។

-អនុមានញែក: ជាវិធីដែលចេញដំណើរពីភាពរួមទៅដោយឡែក។ វិធីទាំងពីរមានទិសដៅផ្ទុយគ្នា តែវាមានទំនាក់ទំនងជាអង្គសិរីរាង្គតែមួយនិងបំពេញឲ្យគ្នាទៅវិញទៅមក។

**គ. ប្រវត្តិសាស្ត្រ Logique**

- ប្រវត្តិសាស្ត្រ: ជាប្រភេទស័ព្ទប្រើប្រាស់ ដើម្បីចង្អុលបង្ហាញដំណាក់កាលរីកចម្រើននៃវត្ថុ បាតុភូតក្នុងពិភពបរានុម័ត។

- Logique: ជាប្រភេទស័ព្ទប្រើប្រាស់សម្រាប់ចង្អុលបង្ហាញភាពរួមសារជាតិចាំបាច់ និងក្រិត្យក្រមក្នុងដំណាក់កាលរីកចំរើននៃវត្ថុ បាតុភូតក្នុងប្រវត្តិសាស្ត្រ។

ប្រវត្តិសាស្ត្រ និង Logique គឺជាវិធីពីរផ្សេងគ្នាតែមិនត្រូវផ្តាច់ចេញពីគ្នានោះទេ ប្រវត្តិ-សាស្ត្រជារាងកាយនៃជីវិត ឯLogique ជាសារជាតិនៃជីវិត។

**ឃ. អរូបី-ជាក់ស្តែង**

អរូបី ជាដំណាក់កាលចលនានៃពុទ្ធិក្នុងគំនិត រីឯជាក់ស្តែងជាវត្ថុសាមញ្ញ ជាវត្ថុដែល

ខួរទទួលតាមរយៈឥន្ទ្រីយារម្មណ៍។ ជាក់ស្ដែង គឺជាឯកភាពនៃផ្នែកជាច្រើន វាស្ដែងឡើងនៅក្នុងដំណាកាលបូកសរុបជាច្រើន វាជាលទ្ធផល។

**៣. សារៈសំខាន់នៃវិធីឧទ្ទេស**

វិធីឧទ្ទេសនេះគេប្រើប្រាស់យ៉ាងទូលំទូលាយសំដៅទៅលើ ៖

- បកស្រាយពន្យល់ឯកសារថ្មីៗ ដែលមានចំណេះដឹងផ្សាភ្ជាប់តាមប្រព័ន្ធកម្ម ក្នុងរយៈពេលមួយដែលមានកំណត់ ។
- អត្ថាធិប្បាយបន្ថែម គឺបង្ហាញពីបញ្ហាស្មុគស្មាញនៅពេលសិស្សជួបប្រទះការលំបាកដែលខ្លួនមិនអាចស្វែងយល់ និងស៊ីជម្រៅទៅតាមកម្រិតយល់ដឹងរបស់ខ្លួនបាន ។
- ធ្វើអត្ថាធិប្បាយ ឬឧទ្ទេសពីបង្ហាញជាក់ស្ដែងដែលទាក់ទងទៅនិងគោលដៅមេរៀនដែលសិស្សបានរៀនរួចមកហើយ ឬកំពុងរៀន ។
- ធ្វើប្រព័ន្ធកម្មទៅលើចំណេះដឹង ដែលសិស្សបានយល់ជ្រួតជ្រាបរួចមកហើយ ។

**៤. ចំណុចខ្លាំង និងចំណុចខ្សោយរបស់វិធីឧទ្ទេស**

**ក. ចំណុចខ្លាំង**

- ជួយសិស្សឱ្យក្ដោបចំណេះដឹងបានជាពិសេសគឺក្ដោបបាននូវបញ្ហាពិបាក ហើយស្មុគស្មាញ ។
- បង្កបាននូវលក្ខណៈងាយស្រួលឲ្យដល់គ្រូក្នុងការជះឥទ្ធិពលទៅលើសតិអារម្មណ៍ និងសញ្ចេតនារបស់សិស្សដោយឆ្លងកាត់តាមរយៈការអធិប្បាយរបស់គ្រូបង្រៀន ។
- ជំរុញសិស្សឲ្យមានចរិតកម្មក្នុងការគិត និងកត់ត្រាចំណុចសំខាន់ៗ ។

**ខ. ចំណុចខ្សោយ**

- ងាយនឹងធ្វើឲ្យសិស្សអសកម្មក្នុងការយកចិត្តទុកដាក់ស្ដាប់
- មិនបានធ្វើឲ្យគ្រូយកចិត្តទុកដាក់សិស្សជិតដល់ទៅលើកម្រិតមធ្យមទៅលើសិស្ស ហើយក៏បានពិនិត្យគ្រប់ជ្រុងជ្រោយរបស់សិស្សនីមួយៗ ។

**៥. ចំណុចសំណូមពរចំពោះវិធីឧទ្ទេស**

- **ទី១ :** ធានាឱ្យបាននូវចរិតអប់រំបែបវិទ្យាសា ស្រ្ត និងចរិតអនុវត្តន៍របស់ខ្លឹមសារនៃវិធីឧទ្ទេស ហើយគួរគប្បីឲ្យមានលក្ខណៈត្រឹមត្រូវ ពិតប្រាកដរបស់ព្រឹត្តិការណ៍ អត្ថន័យ...។

- **ទី២ :** ធានាបាននូវលំដាប់ថ្នាក់ត្រឹមត្រូវ ទៅលើសេចក្ដីអធិប្បាយតាមឯកសារផ្សេងៗ។
- **ទី៣ :** ធានាបាននូវភាពភ្លឺស្វាងច្បាស់លាស់ងាយយល់ក្នុងការធ្វើអត្ថាធិប្បាយតាមឯកសារផ្សេងៗ ។
- **ទី៤ :** ធានាបានូវការប្រុងប្រយ័ត្នរបស់សិស្សក្នុងការស្ដាប់ និងការគិត ។
- **ទី៥ :** ធានាឲ្យសិស្សយល់ច្បាស់អាចកត់ត្រាបាន ។